# ព្រះរាជក្រឹត្យ

នស/រកត/០៦០២/១៦៤

## ស្តីពី

## លក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី ដោយមានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

Downloaded from http://www.khmerlaws.com

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតក្របខ័ណ្ឌ មន្ត្រីសុខាភិបាលមធ្យមរបស់ក្រសួងសុខាភិបាល ដែលត្រូវចាត់ថ្នាក់ក្នុងប្រភេទ " ខ " ដូចមានចែង ក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យ លេខ ជស/រកត/១២៩៧ / ២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំ មុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ស្ថិតនៅក្រោមឱវាទក្រសួងសុខាភិបាល ប្រមូលផ្តុំមន្ត្រីបច្ចេកទេសសុខាភិបាលកំរិតមធ្យម បំរើការងារក្នុងវិស័យសុខាភិបាល តាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង និងគ្រឹះស្ថានសាធារណៈរបស់ក្រសួង ស្ថាប័នរដ្ឋ ។

**មាត្រា ៣.-**

មន្ត្រីនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មានមុខងារជួយដល់មន្ត្រីសុខាភិបាលជាន់ខ្ពស់ក្នុងការសំរេចអនុវត្តការងារ និង អាចបំពេញមុខដំណែងដឹកនាំកំរិតមធ្យម ។

## ជំពូកទី ២

## ឋានន្តរស័ក្តិ និង មុខដំណែង

**មាត្រា ៤.-**

ក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម មាន ៣ ឋានន្តរស័ក្តិ :

- ឋានន្តរស័ក្តិទី ១ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យម ដើមខ្សែពិសេសមាន ៦ ថ្នាក់
- ឋានន្តរស័ក្តិទី ២ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យម ដើមខ្សែមាន ១០ ថ្នាក់
- ឋានន្តរស័ក្តិទី ៣ ឬ ឋានន្តរស័ក្តិ មន្ត្រីសុខាភិបាលមធ្យមមាន ១៤ ថ្នាក់ ។/.

Downloaded from http://www.khmerlaws.com

**មាត្រា ៥.-**

មន្ត្រីសុខាភិបាលមធ្យម អាចកាន់មុខតំណែងគ្រប់គ្រង នៅតាមអង្គភាពបច្ចេកទេសជំនាញនានា របស់ក្រសួងសុខាភិបាល ដូចខាងក្រោម :

- ឋានន្តរស័ក្តិទី ១ : ប្រធានការិយាល័យជំនាញនៅថ្នាក់កណ្តាល អនុប្រធានមន្ទីរសុខាភិបាលខេត្ត ក្រុង
- ឋានន្តរស័ក្តិទី ២ : អនុប្រធានការិយាល័យជំនាញនៅថ្នាក់កណ្តាល ប្រធានការិយាល័យជំនាញនៃមន្ទីរសុខាភិបាលខេត្ត ក្រុង
- ឋានន្តរស័ក្តិទី ៣: អនុប្រធានការិយាល័យជំនាញនៃមន្ទីរសុខាភិបាលខេត្ត ក្រុង ប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ

និងមុខដំណែងឯទៀតដែលមានថ្នាក់ស្មើ នឹងមុខតំណែងខាងលើនៃឋានន្តរស័ក្តិនីមួយៗនៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៣

## ការជ្រើសរើស

**មាត្រា ៦.-**

ការជ្រើសរើសអោយចូលក្នុងក្របខ័ណ្ឌ មន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើសក្នុងចំណោមបេក្ខជនជានិស្សិត និង ឬ ជាមន្ត្រីរាជការ ។ ចំនួនតំណែងក្នុងការជ្រើសរើស សំរាប់បេក្ខជនជានិស្សិតឬសំរាប់បេក្ខជន ជាមន្ត្រីរាជការ តាមផ្នែកនីមួយៗ ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងសុខាភិបាល ។

**មាត្រា ៧.-**

ការប្រលងជ្រើសរើសចូលក្របខ័ណ្ឌក្នុងចំណោមនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត២៨ ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រផ្នែកណាមួយ យ៉ាងទាប ដូចខាងក្រោម :

- សញ្ញាប័ត្រគិលានុបដ្ឋាក គិលានុបដ្ឋាយិកា មធ្យម
- សញ្ញាប័ត្រឆ្មបមធ្យម
- សញ្ញាប័ត្រអ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម
- សញ្ញាប័ត្រព្យាបាលដោយចលនាមធ្យម

និងសញ្ញាប័ត្រជំនាញផ្នែកបច្ចេកទេសផ្សេងៗ និងអមវេជ្ជសាស្ត្រឯទៀត ដែលមានតំលៃស្មើនឹងសញ្ញាប័ត្រខាងលើ ។

ចំពោះមន្ត្រីក្នុងក្របខ័ណ្ឌ ដែលមានសញ្ញាប័ត្រដូចខាងលើ អាចប្រលងចូលក្របខ័ណ្ឌនេះបាន ដោយពុំគិតពីល័ក្ខខ័ណ្ឌ នៃឋានន្តរស័ក្តិ និងប្រភេទក្របខ័ណ្ឌឡើយ ហើយមានអាយុច្រើនបំផុត ៤០ ឆ្នាំ ។ល។

Downloaded from http://www.khmerlaws.com

# ជំពូកទី ៤

## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨.-**

បេក្ខជន ដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមនិស្សិតនិងក្នុងចំណោមមន្ត្រីរាជការ ត្រូវទទួលការបណ្តុះបណ្តាលដំបូងរៀបចំដោយក្រសួងសុខាភិបាល ហើយមានឋានៈជានិស្សិតមន្ត្រីសុខាភិបាលមធ្យម ។

**មាត្រា ៩.-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង និស្សិតមន្ត្រីសុខាភិបាលមធ្យម ត្រូវចាត់អោយទៅបំរើការងារ នៅតាមអង្គភាពសុខាភិបាល ខេត្ត ក្រុង និងថ្នាក់កណ្តាល ដោយផ្អែកះលើលទ្ធផលនៃការបណ្តុះបណ្តាល ហើយត្រូវតែងតាំងជាមន្ត្រីសុខាភិបាលមធ្យមកម្មសិក្សា ដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

មន្ត្រីសុខាភិបាលមធ្យម ដែលជ្រើសរើសចេញពីនិស្សិត ត្រូវឆ្លងកាត់កម្មសិក្សារយៈពេល ១២ខែ ។ ក្រោយពេលបញ្ចប់កម្មសិក្សាសាកល្បងដោយជោគជ័យ មន្ត្រីទាំងនេះត្រូវតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិទី៣ ។

មន្ត្រីសុខាភិបាលមធ្យម ដែលជ្រើសរើសចេញពីមន្ត្រីរាជការរបស់ក្រសួងសុខាភិបាលពុំចាំបាច់ធ្វើកម្មសិក្សាសាកល្បងឡើយ ។ មន្ត្រីរាជការផ្សេងៗទៀតត្រូវធ្វើកម្មសិក្សាសាកល្បងរយៈពេល ០៦ ខែ ។

មន្ត្រីសុខាភិបាលមធ្យម ដែលបានជ្រើសរើសតាមការប្រឡងប្រជែង ក្នុងចំណោមមន្ត្រីរាជការ ត្រូវបញ្ចូលទៅក្នុងឋានន្តរស័ក្តិ ទី៣ ក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់ លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ។

មន្ត្រីសុខាភិបាលមធ្យម ដែលធ្វើកម្មសិក្សា មិនបានសំរេចជោគជ័យត្រូវអនុញ្ញាតអោយបន្តធ្វើកម្មសិក្សានៅលើកទី២ទៀត។ ក្នុងករណីមិនទទួលបានជោគជ័យជាលើកទី២ នេះ កម្មសិក្សាការីដែលជ្រើសរើសពីនិស្សិត ត្រូវលុបឈ្មោះចេញ កម្មសិក្សាការីដែលជ្រើសរើសពីមន្ត្រីរាជការត្រូវបញ្ជូនទៅក្របខ័ណ្ឌដើមវិញ ដោយគិតរយៈពេលបណ្តុះបណ្តាលដំបូង និងកម្មសិក្សា សំរាប់អតីតភាពការងារ ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី៣ នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើឡើងដោយអនុក្រឹត្យ ។

# ជំពូកទី ៥

## ការតែងតាំង

**មាត្រា ១០.-**

ក្រោយពេលតាំងស៊ប់ក្នុងក្របខ័ណ្ឌ មន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម អាចត្រូវតែងតាំងក្នុងមុខតំណែងទំនេរណាមួយ ដូចមានកំណត់ក្នុងមាត្រា៣ និងមាត្រា៥ ខាងលើ ។ល។

Downloaded from http://www.khmerlaws.com

## ជំពូកទី ៦
## ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១.-**

មន្ត្រីសុខាភិបាលមធ្យម អាចត្រូវដាក់អោយស្ថិតក្រៅក្របខ័ណ្ឌដើម ឬ ក្រៅតំណែងដើម ដើម្បីទៅបំរើការនៅក្រសួង ស្ថាប័ន ឬអង្គភាពផ្សេងណាមួយ តាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូកទី ៧
## ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិ

**មាត្រា ១២.-**

មន្ត្រីសុខាភិបាលមធ្យម ត្រូវដំឡើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមល័ក្ខខ័ណ្ឌដូចបានចែងក្នុង មាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

លក្ខណៈសម្បត្តិ ជាមូលដ្ឋានសំរាប់ការពិនិត្យដំឡើងថ្នាក់មានដូចខាងក្រោម :

- គំនិតផ្តួចផ្តើមថ្លៃប្រឌិត និងលទ្ធផលការងារ
- ស្មារតីទទួលខុសត្រូវ វិន័យការងារ មនសិការវិជ្ជាជីវៈ
- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- ប្រសិទ្ធិភាពក្នុងការដឹកនាំ និង គ្រប់គ្រង
- សាមគ្គីធម៌ និង សីលធម៌រស់នៅ ។

ការដំឡើងថ្នាក់នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ តាមវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១៣.-**

គោលការណ៍នៃការដំឡើងឋានន្តរស័ក្តិ តាមធម្មតា ត្រូវដំឡើងទៅក្នុងថ្នាក់ដំបូងនៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវដំឡើងទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍ខ្ពស់លើបន្ទាប់ ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ចំនួនតំណែងក្នុងឋានន្តរស័ក្តិនីមួយៗ ត្រូវកំណត់ដូចខាងក្រោម :

- ៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី១
- ២៥ % ជាអតិបរមា សំរាប់ឋានន្តរស័ក្តិទី២
- ៧០ % ឡើងទៅ សំរាប់ឋានន្តរស័ក្តិទី៣ ។ល។

Downloaded from http://www.khmerlaws.com

ការដំឡើងឋានន្តរស័ក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងដំឡើងឋានន្តរស័ក្តិ និងការវាយតំលៃ របស់ឋានានុក្រមគ្រប់គ្រង ឬ តាមរយៈការបណ្តុះបណ្តាលបន្តនៅក្នុង ឬក្រៅប្រទេស។

ការដំឡើងថ្នាក់ និង ការដំឡើងឋានន្តរស័ក្តិនៃ មន្ត្រីសុខាភិបាលមធ្យម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

**មាត្រា ១៤.-**

សន្ទស្សន៍ សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌ និងតំលៃឯកតានៃ សន្ទស្សន៍ ត្រូវបានកំណត់ស្របតាមមាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំ របស់មន្ត្រីរាជការ ។

## ជំពូកទី ៨

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៥.-**

មន្ត្រីសុខាភិបាលមធ្យម ដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬ ការបណ្តុះបណ្តាលបន្តរយៈពេលសរុប យ៉ាងតិច ០៦ ខែ ក្នុងជំនាញរបស់ខ្លួន ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សា ត្រូវទទួលការដំឡើងថ្នាក់ ១ថ្នាក់ជាស្វ័យប្រវត្តិ តាមវេនជ្រើសរើស ។

**មាត្រា ១៦.-**

មន្ត្រីសុខាភិបាលមធ្យម ត្រូវដាក់អោយចូលនិវត្តន៍ ពេលដល់អាយុ ៦០ ឆ្នាំ ។

ការដាក់អោយចូលនិវត្តន៍ត្រូវសំរេចដោយប្រកាសរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

ចំនួនដំបូងនៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលមធ្យម ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីរាជការ ដែលបច្ចុប្បន្ន កំពុងបំពេញមុខងារនិងមុខតំណែងពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងវិស័យសុខាភិបាលនៅរដ្ឋបាលកណ្តាល និង ខេត្ត ក្រុង របស់ក្រសួងស្ថាប័នរដ្ឋ ហើយដែលមានសញ្ញាប័ត្រណាមួយ ដូចមានចែងក្នុងមាត្រា៧ នៃព្រះរាជក្រឹត្យនេះ។ល។

Downloaded from http://www.khmerlaws.com

**មាត្រា ១៨.-**

មន្ត្រីសុខាភិបាលមធ្យម ដែលបានតែងតាំងរួចហើយក្នុងមុខតំណែងគ្រប់គ្រងណាមួយ ត្រូវអនុញ្ញាតអោយបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ត្រូវផ្លាស់ប្តូរមុខតំណែងដែលជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**មាត្រា ១៩.-**

បទប្បញ្ញត្តិណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ២០.-**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ។

**មាត្រា ២១.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។/.

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ ២០០២

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហនុ**

នស/រកត.០៦,០៦.០០១៧៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
ព្រះមហាក្សត្រ សូមឡាយព្រះហស្ថលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ១៤១៩ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែ មិថុនា ឆ្នាំ២០០២

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឈាឌី តាន់**

Downloaded from http://www.khmerlaws.com